# កិច្ចសន្យាធានារ៉ាប់រងលើហានិភ័យសម្រាប់ការតម្លើង

**ដោយហេតុថា** បុគ្គលទទួលការធានារ៉ាប់រងដូចមានឈ្មោះនៅក្នុងឧបសម្ព័ន្ធនេះ បានដាក់ជូនទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុន ប៉ាក ភីអិលស៊ី ដែលមានឈ្មោះខាងលើ (តទៅនេះហៅថា "ក្រុមហ៊ុនធានារ៉ាប់រង") នូវសំណើជាលាយលក្ខណ៍អក្សរតាមរយៈការបំពេញកម្រងសំនួររួមគ្នាជាមួយនឹង សេចក្តីថ្លែងការណ៍ណាមួយផ្សេងទៀត ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរដោយបុគ្គលទទួលការធានារ៉ាប់រងតាមគោលបំណងរបស់ កិច្ចសន្យាធានារ៉ាប់រងនេះដែលតទៅត្រូវបានបញ្ចូលនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ ។

កិច្ចសន្យាធានារ៉ាប់រងនេះ សំដៅចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រងដែលបានបង់ទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងនូវបុព្វលាភធានារ៉ាប់រងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ និងយោងទៅតាម ខ ករណីលើកលែង បញ្ញត្តិ លក្ខខណ្ឌដែលមានចែងតទៅនេះ ឬបដិលេខក្រុមហ៊ុនធានារ៉ាប់រង នឹងផ្តល់សំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងលក្ខណៈ និងវិសាលភាពដូចមានចែងដូចខាងក្រោម ។

**ករណីលើកលែងទូទៅ**

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនផ្តល់សំណងដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងឡើយ ចំពោះករណីនៃការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដែលបណ្តាលមកពី ឬកើតឡើង ឬធ្វើឲ្យកាន់តែធ្ងន់ធ្ងរដោយផ្ទាល់ ឬដោយប្រយោលដោយសារ :

ក) សង្គ្រាម ការឈ្លានពាន ទង្វើរបស់សត្រូវបរទេស អរិភាព (ទោះបីជាសង្គ្រាមនោះត្រូវបានប្រកាស ឬមិនប្រកាសក៏ដោយ) សង្គ្រាមស៊ីវិល ឧទ្ទាមកម្ម ការធ្វើបដិវត្តន៍ ការចលាចល ការបះបោរ កុប្បកម្ម កូដកម្ម ការមិនឲ្យបុគ្គលិក ឬកម្មករចូលកន្លែងធ្វើការ ការរំដើបរំជួលស៊ីវិល អំណាចយោធា ឬការដណ្តើមអំណាច ក្រុមមនុស្សព្យាបាទ ឬមនុស្សដែលតំណាងឲ្យ ឬដែលមានទំនាក់ទំនងជាមួយនឹងស្ថាប័ននយោបាយ ការរួមគំនិតក្បត់ ការរឹបអូស ការកេណ្ឌ ការប្តឹងផ្តល់ ឬបំផ្លិចបំផ្លាញ ឬក៏ធ្វើអោយខូចខាតដោយបញ្ជាណាមួយរបស់រដ្ឋាភិបាលដោយស្របច្បាប់ ឬមិនស្របច្បាប់ ឬដោយអាជ្ញាធរសាធារណៈ

ខ) ប្រតិកម្មនុយក្លេអ៊ែរ ចំហាយដែលភាយចេញពីជាតិនុយក្លេអ៊ែរ ឬការឆ្លងដោយធាតុវិទ្យុសកម្ម ។

គ) សកម្មភាពដោយចេតនា ឬការធ្វេសប្រហែលដោយចេតនារបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬតំណាងរបស់ខ្លួន ។

ឃ) ការឈប់សកម្មភាពការងារ ទោះទាំងស្រុង ឬដោយផ្នែក ។

**ង) បដិលេខចំពោះការលើកលែងករណីភេរវកម្ម**

ទោះបីជាមានបទប្បញ្ញត្តិណាមួយផ្ទុយទៅនឹងការធានារ៉ាប់រងនេះ ឬការឯកភាពណាមួយក៏ដោយក៏មានការព្រមព្រៀងគ្នាថា ការធានារ៉ាប់រងនេះមិនរួមបញ្ចូលការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោល ដែលបណ្តាលមកពី ឬពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មណាមួយ ដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ណាមួយផ្សេងទៀត ដែលរួម ចំណែក ឬជាលទ្ធផលបង្កឲ្យមានការបាត់បង់នោះឡើយ ។

សម្រាប់គោលបំណងនៃបដិលេខនេះ សកម្មភាពភេរវកម្មសំដៅលើសកម្មភាពមួយដែលមានជាអាទិ៍ដូចជា ការប្រើកម្លាំង ឬអំពើហិង្សា និង/ឬ ការគម្រាមកំហែងប្រើកម្លាំង ឬអំពើហិង្សារបស់បុគ្គលណាមួយ ឬក្រុមណាមួយរបស់បុគ្គល បើទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាម ឬពាក់ព័ន្ធនឹងអង្គភាពណាមួយ ឬរដ្ឋាភិបាល សម្រាប់គោលបំណងនយោបាយសាសនា មនោ

គមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ ដែលរួមមានចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬដើម្បីបង្កការភ័យខ្លាចដល់សាធារណជន ឬក្រុមណាមួយនៃ សាធារណជននោះ ។

បដិ្ឋលេខនេះ ក៏មិនរួមបញ្ចូលផងដែរនូវការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយទាំងឡាយណា ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោល កើតឡើងមកពី ឬពាក់ព័ន្ធនឹងការចាត់វិធានការណាមួយដើម្បីគ្រប់គ្រង ទប់ស្កាត់ បង្ក្រាប ឬទាក់ទងនឹងសកម្មភាព ភេរវកម្មតាមវិធីណាមួយ ។

តាមរយៈហេតុផលនៃការលើកលែងនេះ ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ មិនត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ បន្ទុកនៃការបញ្ជាក់អ្វីដែលផ្ទុយ ត្រូវធ្លាក់លើបុគ្គលដែលត្រូវបានធានារ៉ាប់រង ។

ក្នុងករណីដែលផ្នែកណាមួយនៃបដិ្ឋលេខនេះត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកផ្សេងទៀតដែលនៅ សល់ នៅតែស្ថិតនៅជាធរមាន និងមានសុពលភាពពេញលេញ ។

NMA2921
០៨/១០/២០០១

**ច) ការបញ្ជាក់ពីលក្ខខណ្ឌទាក់ទិននឹងព័ត៌មានវិទ្យា**

ការខូចខាតលើទ្រព្យសម្បត្តិដែលត្រូវបានទទួលធ្វើសំណង ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ មានន័យថាជាការខូចខាត ជារូបវ័ន្តចំពោះ ទ្រព្យសម្បត្តិនោះ ។ ការខូចខាតលើទ្រព្យសម្បត្តិជារូបវ័ន្ត មិនរាប់បញ្ចូលការខូចខាតលើទិន្នន័យ ឬសូហ្វវែរ៍ ជាពិសេសការប្រែប្រួលបណ្តាលឲ្យខូចខាតដល់ទិន្នន័យ សូហ្វវែរ៍ ឬកម្មវិធីកុំព្យូទ័រ ដោយសារតែការលុបចោល ការបង្ខូច ឬការកែប្រែទំរង់ដើម។

កិច្ចសន្យាធានារ៉ាប់រងនេះ មិនរាប់បញ្ចូលនូវការខាតបង់ដូចខាងក្រោមនេះ :

ក. ការខូចខាតលើទ្រព្យសម្បត្តិជារូបវ័ន្ត មិនត្រូវរាប់បញ្ចូលចំពោះការខូចខាតលើទិន្នន័យ ឬសូហ្វវែរ៍ ជាពិសេសការប្រែប្រួលបណ្តាលឲ្យខូចខាតដល់ទិន្នន័យ សូហ្វវែរ៍ ឬកម្មវិធីកុំព្យូទ័រដោយសារតែការលុបចោល ការកែប្រែ ឬការធ្វើឲ្យខូចដល់ទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដើម និងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការអាក់ខានផ្នែកអាជីវកម្ម ដែលជាលទ្ធផលបណ្តាលមកពីការខាតបង់ ឬការខូចខាតទាំងនេះ។

ខ. ការខាតបង់ ឬការខូចខាតដែលបណ្តាលមកពីការធ្វើអោយខ្សោយដល់ការបំពេញមុខងារ មិនអាចប្រើប្រាស់ ឬទទួលបានទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការធ្វើឲ្យខ្សោយដល់ការបំពេញមុខងារមិនអាចប្រើប្រាស់ ឬទទួលបានទិន្នន័យ ឬកម្មវិធីកុំព្យូទ័រ និងការខាតបង់ផ្នែកហិរញ្ញវត្ថុដែលបណ្តាលមកពីការអាក់ខានផ្នែកអាជីវកម្មដែលលទ្ធផលបណ្តាលមកពីការខាតបង់ ឬការខូចខាតទាំងនេះ។

(Munich Re)

នៅក្នុងសកម្មភាព បណ្តឹង ឬដំណើរការក្តីណាមួយដែលក្រុមហ៊ុនធានារ៉ាប់រងចោទប្រកាន់ថា ដោយហេតុផលបទប្បញ្ញត្តិនៃការលើកលែង "១" ខាងលើ ការបាត់បង់ ការបំផ្លាញ ការខូចខាត ឬការទទួលខុសត្រូវណាមួយ មិនត្រូវបានធានាដោយការធានារ៉ាប់រងនេះទេ នោះការផ្តល់ភស្តុតាងថា ការបាត់បង់ ការបំផ្លាញ ការខូចខាត ឬការទទួលខុសត្រូវបែបនេះ ស្ថិតនៅក្រោមការធានារ៉ាប់រង ត្រូវក្លាយជាបន្ទុករបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

**រយៈពេលធានារ៉ាប់រង**

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងត្រូវចាប់ផ្តើម ទោះបីជាវាផ្ទុយទៅនឹងកាលបរិច្ឆេទដែលចែងនៅក្នុងគម្រោងការងារនេះក៏ដោយ នៅពេលដែលចាប់ផ្តើមការងារ ឬក្រោយពេលដកការងារនេះចេញពីគម្រោងការងារនៅទីកន្លែងការដ្ឋាន និងត្រូវបន្តរហូតដល់ភ្លាមៗបន្ទាប់ពីកាន់កាប់ ឬបន្ទាប់ពីប្រតិបត្តិបការសាកល្បងដំបូង ឬការផ្ទុកសាកល្បងត្រូវបញ្ចាប់ ចំពោះប្រតិបត្តិបការសាកល្បងដំបូង ឬការផ្ទុកសាកល្បងនេះ ថាតើមួយណាត្រូវធ្វើមុន ប៉ុន្តែមិនត្រូវលើសពីបួនសប្តាហ៍ឡើយ (ប្រសិនបើគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុន) ពីកាលបរិច្ឆេទនៃការចាប់ផ្តើមការសាកល្បង។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើផ្នែកណាមួយនៃគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីនមួយ ឬច្រើនគ្រឿងត្រូវបានធ្វើការសាកល្បង និង/ឬដាក់ឲ្យប្រើប្រាស់ ឬត្រូវបានកាន់កាប់ ការធានាចំពោះផ្នែកនៃគ្រឿងចក្រ ឬម៉ាស៊ីនោះ និងការទទួលខុសត្រូវណាមួយដែលបណ្តាលមកពីករណីបែបនោះដែលការធានាបន្តសម្រាប់ផ្នែកដែលនៅសល់។

ក្នុងករណីរបស់មួយទឹក ការធានារ៉ាប់រងដូចខាងក្រោមនេះ ទោះយ៉ាងណាក៏ដោយនឹងត្រូវបញ្ឈប់ភ្លាមនៅពេលការចាប់ផ្តើមធ្វើការសាកល្បង។

នៅពេលចុងក្រោយបំផុត ការធានារ៉ាប់រងនឹងត្រូវអស់សុពលភាពតាមកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងគម្រោងការងារ។

ការពន្យារពេលវេលាធានារ៉ាប់រងណាមួយត្រូវមានការព្រមព្រៀងជាមុនជាលាយលក្ខណ៍អក្សរពីសំណាក់ក្រុមហ៊ុនធានារ៉ាប់រង។

**លក្ខខណ្ឌទូទៅ**

១. ការគោរពឲ្យបានត្រឹមត្រូវ និងអនុវត្តតាមលក្ខខណ្ឌកំណត់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដរាបណាវាទាក់ទងនឹងអ្វីដែលត្រូវធ្វើ ឬប្រតិបត្តិតាមដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង និងការពិតនៃសេចក្តីបញ្ជាក់ និងចម្លើយនៅក្នុងកម្រងសំនួរ និងសេចក្តីស្នើសុំដែលធ្វើឡើងដោយ បុគ្គលដែលត្រូវបានធានារ៉ាប់រង គឺជាលក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវនៃក្រុមហ៊ុនធានារ៉ាប់រង ។

២. គម្រោងការងារ និងផ្នែកនានា ត្រូវចាត់ទុកថាត្រូវបានដាក់បញ្ចូល និងបង្កើតបានជាផ្នែកនៃកិច្ចសន្យាធានារ៉ាប់រងនេះ ហើយពាក្យ "កិច្ចសន្យាធានារ៉ាប់រងនេះ" ទោះបីត្រូវបានប្រើប្រាស់នៅចំនុចណាក៏ដោយក្នុងកិច្ចសន្យានេះត្រូវអានដោយបូកបញ្ចូលឧបសម្ព័ន្ធ និងផ្នែកផ្សេងៗ ។ ពាក្យពេចន៍ ឬឃ្លាណាមួយដែលអត្ថន័យរបស់វាត្រូវបានភ្ជាប់នៅក្នុងផ្នែកណាមួយនៃកិច្ចសន្យាធានារ៉ាប់រងនេះ ឬក្នុងឧបសម្ព័ន្ធ ឬ ផ្នែកនានាត្រូវមានន័យបែបនេះទោះបីជានៅចំណុចណាក៏ដោយ ។

៣. បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវមានវិធានការប្រុងប្រយ័ត្នសមហេតុផលដោយត្រូវចំណាយផ្ទាល់ខ្លួន និងគោរពទៅតាមអនុសាសន៍សមហេតុផលរបស់ក្រុមហ៊ុនធានារ៉ាប់រងដើម្បីបង្ការការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដោយមានលក្ខខណ្ឌតម្រូវស្របច្បាប់ និងអនុសាសន៍របស់អ្នកផលិត ។

៤. ក) នៅពេលវេលាដ៏សមរម្យណាមួយតំណាងរបស់ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិធ្វើការពិនិត្យពិច័យ និងត្រួតពិនិត្យហានិភ័យ ហើយបុគ្គលទទួលការធានារ៉ាប់រងត្រូវផ្តល់ជូនតំណាងបុគ្គលធានារ៉ាប់រងនូវសេចក្តីសម្អិត និងព័ត៌មានសំខាន់ៗនានាសម្រាប់ធ្វើការវាយតម្លៃហានិភ័យ ។

ខ) បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រុមហ៊ុនធានារ៉ាប់រងតាមទូរលេខ និងជាលាយលក្ខណ៍អក្សរអំពីអ្វីដែលផ្លាស់ប្តូរនៅក្នុងហានិភ័យ និងមូលហេតុដោយត្រូវរ៉ាប់រងចំណាយផ្ទាល់ខ្លួនចំពោះការប្រុងប្រយត្ន័បន្ថែមដែលត្រូវអនុវត្តតាមកាលៈទេសៈតម្រូវ ហើយវិសាលភាពគ្របដណ្តប់ និង/ឬបុព្វលាភធានារ៉ាប់រងត្រូវធ្វើការកែសម្រួលតាមនោះ ប្រសិនបើចាំបាច់ ។

បុគ្គលដែលត្រូវបានធានារ៉ាប់រងមិនត្រូវ ឬមិនអនុញ្ញាតឲ្យធ្វើការកែប្រែណាមួយ ដែលធ្វើឲ្យហានិភ័យកើនឡើងឡើយ ប្រសិនបើគ្មានការបញ្ជាក់ពីការបន្តការធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងជាលាយលក្ខណ៍អក្សរនោះទេ ។

៥. នៅក្នុងករណីនៃហេតុការណ៍ណាមួយដែលអាចឲ្យមានការទាមទារសំណងតាមកិច្ចសន្យាធានារ៉ាប់រងនេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវ :

ក) ជូនដំណឹងជាបន្ទាន់ដល់ក្រុមហ៊ុនធានារ៉ាប់រងតាមទូរស័ព្ទ ឬទូរលេខ ក៏ដូចជាតាមលិខិតជាលាយលក្ខណ៍អក្សរដោយផ្តល់ជូននូវ ការចង្អុលបង្ហាញពីលក្ខណៈ និងវិសាលភាពនៃការបាត់បង់ និងការខូចខាត ។

ខ) អនុវត្តគ្រប់ចំនុចដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយវិសាលភាពនៃការបាត់បង់ និងខូចខាត ។

គ) រក្សាទុកនូវផ្នែកដែលខូចខាត និងធ្វើអោយវាស្ថិតក្នុងភាពអាចពិនិត្យបានដោយតំណាង ឬអ្នកអង្កេតការរបស់ក្រុមហ៊ុន ធានារ៉ាប់រង ។

ឃ) ផ្តល់នូវព័ត៌មាន និងឯកសារភស្តុតាងនានា នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងអាចនឹងទាមទារ ។

ង) ផ្តល់ដំណឹងជូនអាជ្ញាធរនគរបាលក្នុងករណីដែលមានការបាត់បង់ ឬខូចខាតដោយសារចោរកម្ម ឬការលបចូលលួច ។

ក្នុងករណីណាក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងមិនទទួលខុសត្រូវចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវណាមួយ ដែលគ្មានការជូនដំណឹងក្នុងរយៈពេល ១៤ថ្ងៃក្រោយពេលកើតហេតុឡើយ ។

នៅពេលដែលការជូនដំណឹង ត្រូវបានផ្តល់ជូនទៅក្រុមហ៊ុនធានារ៉ាប់រងតាមលក្ខខណ្ឌនេះ បុគ្គលដែលត្រូវបានធានារ៉ាប់រងអាចធ្វើការជួសជុល ឬផ្លាស់ប្តូរចំពោះការខូចខាតបន្តិចបន្តួចណាមួយ ក្នុងករណីណាក៏ដោយ តំណាងរបស់ក្រុមហ៊ុនធានារ៉ាប់រងត្រូវមានឱកាសពិនិត្យ លើការបាត់បង់ ឬខូចខាតមុនពេលដែលមានការ ជួលជុល ឬកែប្រែណាមួយ ។ ប្រសិនបើតំណាងរបស់ក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើការ ពិនិត្យក្នុងរយៈពេលណាមួយ ដែលអាចចាត់ទុកថាសមល្មមតាមកាលៈទេសៈនោះទេ បុគ្គលដែលត្រូវបានធានារ៉ាប់រងមានសិទ្ធិធ្វើការជួសជុល ឬផ្លាស់ប្តូរបាន ។
ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយអនុលោមតាមកិច្ចសន្យាធានារ៉ាប់រងនេះ ចំពោះវត្ថុណាមួយដែលរងការខូចខាត នោះនឹងត្រូវបញ្ចប់ ប្រសិនបើវត្ថុនោះមិនត្រូវបានជួសជុលអោយបានត្រឹមត្រូវ ដោយគ្មានការពន្យារពេល ។

៦. ដោយប្រើសោហ៊ុយរបស់ក្រុមហ៊ុនធានារ៉ាប់រង បុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវធ្វើ និងយល់ព្រមក្នុងការធ្វើ និងអនុញ្ញាតឲ្យធ្វើនូវសកម្មភាព និងការងារនេះតាមការចាំបាច់ ឬការតម្រូវដោយក្រុមហ៊ុនធានារ៉ាប់រងជាប្រយោជន៍នៃសិទ្ធិ ឬដំណោះស្រាយណាមួយ ឬនៃការសម្រួល ឬសំណងទូទាត់ពីភាគី (ក្រៅពីបុគ្គលទទួលការធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ) ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវ ឬមានសិទ្ធិ ឬកាតព្វកិច្ចបង់ថ្លៃជូន ឬធ្វើការប៉ះប៉ូវការបាត់បង់ ឬខូចខាតតាមកិច្ចសន្យាធានារ៉ាប់រងនេះ ទោះជាសកម្មភាព ឬបញ្ហាបែបនេះមានលក្ខណៈ ឬក្លាយជាចាំបាច់ ឬត្រូវបានទាមទារមុន ឬក្រោយការសងសំណងដោយក្រុមហ៊ុន ធានារ៉ាប់រងអោយទៅបុគ្គលដែលត្រូវបានធានារ៉ាប់រងក៏ដោយ ។

៧. ប្រសិនបើចំនួនទឹកប្រាក់ដែលត្រូវបង់មានភាពខុសគ្នាតាមកិច្ចសន្យាធានារ៉ាប់រងនេះ (ម្យ៉ាងទៀតសំណងត្រូវបានទទួលយក) ភាពខុសគ្នាបែបនេះ ត្រូវអាស្រ័យទៅតាមសេចក្តីសំរេចរបស់អាជ្ញាកណ្តាលដែលនឹងតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគី ទៅលើភាពខុសគ្នា ឬប្រសិនបើពួកគេមិនយល់ព្រមតាមអាជ្ញាកណ្តាលតែម្នាក់ទេនោះដើម្បីមានសេចក្តីសម្រេចពីអាជ្ញាកណ្តាលពីររូបដែលម្នាក់ត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ ក្នុងរយៈពេលមួយខែក្រោយបន្ទាប់ពីមានការទាមទារជាលាយលក្ខណ៍អក្សរឲ្យធ្វើដូច្នេះដោយភាគីណាមួយ ឬក្នុងករណីដែលអាជ្ញាកណ្តាលមិនយល់ព្រម អាជ្ញាកណ្តាលម្នាក់ទៀតនឹងត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយអាជ្ញាកណ្តាលពីររូបនោះមុនពេលចូលជាសំអាង ។ អាជ្ញាកណ្តាលនេះត្រូវអង្គុយជាមួយអាជ្ញាកណ្តាលពីររូបនោះ នឹងធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ពួកគេ ។ សេចក្តីសម្រេចរបស់មជ្ឈត្តកម្ម គឺជាលក្ខខណ្ឌមុនពេលផ្តល់សិទ្ធិអោយធ្វើសកម្មភាពប្រឆាំងនឹងក្រុមហ៊ុនធានារ៉ាប់រង ។

៨. ប្រសិនបើការទាមទារសំណងមានលក្ខណៈក្លែងបន្លំ ឬប្រសិនបើសេចក្តីប្រកាសក្លែងក្លាយត្រូវបានគេធ្វើឡើង ឬប្រើប្រាស់ក្នុងការគាំទ្រ ឬប្រសិនបើមធ្យោបាយ ឬឧបករណ៍ក្លែងបន្លំត្រូវបានយកមកប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬនរណាម្នាក់ធ្វើជាតំណាងអោយគាត់ទទួលបានផលប្រយោជន៍តាមកិច្ចសន្យាធានារ៉ាប់រងនេះ ឬប្រសិនបើការទាមទារសំណងត្រូវបានច្រានចោល ហើយគ្មានសកម្មភាព ឬបណ្តឹងអ្វីចាប់ផ្តើមក្នុងរយៈពេលបីខែក្រោយការច្រានចោលនេះ ឬក្នុងករណីមជ្ឈត្តភាពកើតឡើងដូចបានរៀបរាប់រួចមកហើយក្នុងរយៈពេលបីខែក្រោយពីអាជ្ញាកណ្តាលមួយរូប ឬច្រើនរូប ឬមជ្ឈត្តករបានចេញសេចក្តីសម្រេរបស់ពួកគេ រាល់ផលប្រយោជន៍ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបាត់បង់ ។

៩. ប្រសិនបើនៅពេលដែលមានការទាមទារសំណងណាមួយកើតឡើងតាមកិច្ចសន្យាធានារ៉ាប់រងនេះមានការធានារ៉ាប់រងផ្សេងទៀតដែលធានារ៉ាប់រងលើការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដូចគ្នា ក្រុមហ៊ុនធានារ៉ាប់រងមិនទទួលខុសត្រូវក្នុងការធ្វើសំណង ឬរួមវិភាគទានច្រើនជាងសមមាត្រនៃការទាមទារសំណងចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវឡើយ ។

១០. ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ឈប់នៅពេលណាមួយ តាមសំណើរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយជូន ដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង្វិលសងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងវិញចំនួនកៅសិបភាគរយ (៩០%) នៃបុព្វលាភធានារ៉ាប់រងដែលនៅសល់ សម្រាប់រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃសុំបញ្ឈប់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដោយក្នុងលក្ខខណ្ឌថាពុំមានបណ្តឹងទាមទារសំណងណាមួយ កើតឡើងក្នុងអំឡុងពេលនៃការធានារ៉ាប់រងនេះទេ។ កិច្ចសន្យាធានារ៉ាប់រងនេះ ក៏អាចត្រូវបានបញ្ឈប់ផងដែរតាមជម្រើសរបស់ក្រុមហ៊ុន ដោយធ្វើការជូនដំណឹង ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃជាមុនទៅកាន់អាសយដ្ឋាន ដែលគេស្គាល់ចុងក្រោយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងករណីនេះលោកអ្នកមានសិទ្ធិទទួលបានការបង្វិលសងបុព្វលាភមកវិញ តាមសមាមាត្រនៃបុព្វលាភសម្រាប់រយៈពេល ដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃសុំបញ្ឈប់ការ ធានារ៉ាប់រង។

រាល់ការសុំបញ្ឈប់ការធានារ៉ាប់រងលោកអ្នកនឹងមិនត្រូវបានបង្វិលសងនូវបុព្វលាភធានារ៉ាប់រងឡើយប្រសិនបើបុព្វលាភនោះត្រូវបានបង់ក្នុងកម្រិតអប្បបរមា។

១១. **លក្ខខណ្ឌធានាចំពោះបុព្វលាភធានារ៉ាប់រង**

លក្ខខណ្ឌសំខាន់បំផុត និងដាច់ខាតនៃកិច្ចសន្យាធានារ៉ាប់រងនេះ គឺប្រាក់បុព្វលាភដែលដល់ពេលកំណត់ត្រូវបង់ និងទទួលដោយក្រុមហ៊ុនយើងខ្ញុំនៅក្នុងរយៈពេលសាមសិបថ្ងៃ (៣០) គិតចាប់ពីថ្ងៃចាប់ផ្តើមនៃកិច្ចសន្យាធានារ៉ាប់រង/បដិលេខ/បន្តវិញ្ញាបនប័ត្រធានារ៉ាប់រងថ្មីនេះ។

ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពទេ កិច្ចសន្យានេះត្រូវចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនយើងខ្ញុំមាន

សិទ្ធិទទួលបានបុព្វលាភតាមសមាមាត្រសម្រាប់រយៈពេលដែលក្រុមហ៊ុនស្ថិតនៅក្នុងហានិភ័យ។

នៅពេលដែលបុព្វលាភដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារដែលទទួលការអនុញ្ញាតរបស់ក្រុមហ៊ុនយើងខ្ញុំ ការបង់បុព្វលាភនេះត្រូវបានចាត់ទុកថាត្រូវបានទទួលដោយក្រុមហ៊ុនយើងខ្ញុំ សម្រាប់គោលដៅនៃការធានានេះ ហើយក្រុមហ៊ុនយើងខ្ញុំមានបន្ទុកក្នុងការបង្ហាញភស្តុតាងផ្ទុយថា បុព្វលាភនេះត្រូវបានទទួលដោយបុគ្គលម្នាក់ រួមទាំងភ្នាក់ងារធានារ៉ាប់រងផងដែរ ដែលពុំត្រូវបានអនុញ្ញាតឲ្យទទួលបុព្វលាភនេះ។

រាល់លក្ខខណ្ឌ និងខចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

**១២. ខចែងស្តីអំពីការដាក់កំហិតទណ្ឌកម្មនិងករណីលើកលែង (LMA3100)**

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់ អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយ ដែលការផ្តល់ប្រាក់សំណង ឬ អត្ថប្រយោជន៍ទាំងនោះធ្វើឲ្យក្រុមហ៊ុនធានារ៉ាប់រងប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្ម របស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ។

## ផ្នែកទី១ - ការខូចខាតសម្ភារៈ

ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមជាមួយនឹងបុគ្គលដែលត្រូវបានធានារ៉ាប់រងថា ប្រសិនបើពេលណាមួយក្នុងកំឡុងរយៈពេលនៃការធានារ៉ាប់រងលើសម្ភារៈ ឬផ្នែកណាមួយនៃសម្ភារៈនោះចុះក្នុងឧបសម្ព័ន្ធទទួលរងនូវការបាត់បង់ ឬខូចខាតដោយចៃដន្យដែលបណ្តាលមកពីមូលហេតុមួយ ក្រៅពីមូលហេតុទាំងឡាយណាដែលបានលើកលែងយ៉ាងជាក់លាក់ទាំងនោះ ក្នុងលក្ខណៈនៃការជួសជុល ឬផ្លាស់ប្តូរ ជាចាំបាច់ ក្រុមហ៊ុនធានារ៉ាប់រងនឹងសងទូទាត់ទៅឲ្យបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះការបាត់បង់ ឬខូចខាតនេះ ដែលតទៅនឹង ផ្តល់ជូនជាសាច់ប្រាក់ ការផ្លាស់ប្តូរ ឬជួសជុល (តាមការជ្រើសរើសរបស់ពួកគេ) រហូតដល់ចំនួនដែលមិនលើសពីអ្វីដែលមានចែងនៅ ក្នុងឧបសម្ព័ន្ធនៃចំនួនទឹកប្រាក់សរុបដែលផ្ទុយពីនេះ និងដែលមិនលើសពីហេតុការណ៍ណាមួយនូវដែនកំណត់នៃការសងទូទាត់ណា ដែលអាចធ្វើទៅបាន ហើយដែលមិនលើសពីចំនួននៃការចំណាយសរុបនៅក្នុងឧបសម្ព័ន្ធដែលត្រូវធានារ៉ាប់រងដូចខាងក្រោម ។

ក្រុមហ៊ុនធានារ៉ាប់រងក៏នឹងចេញសងជូនដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងផងដែរនូវតម្លៃបោសសម្អាតកាកសំណល់ក្នុងហេតុការណ៍ណាមួយដែលនាំឲ្យមានការទាមទារសំណងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ដែលបានបញ្ជាក់ពីចំនួនដាច់ដោយឡែក ដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ។

**ការលើកលែងពិសេសចំពោះផ្នែកទី ១**

ទោះបីយ៉ាងណាក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលខុសត្រូវចំពោះ

ក) កម្រិតមិនធ្វើសំណងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ដែលត្រូវអនុវត្តតាមដោយអ្នកដែលត្រូវបានធានារ៉ាប់រងនៅក្នុងហេតុការណ៍ណាមួយដែលកើតឡើង

ខ) ការបាត់បង់ផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ ដោយរាប់បញ្ចូលទាំងការផាកពិន័យ ការខាតបង់ដោយសារតែការពន្យាពេល ការខ្វះចន្លោះនៃការអនុវត្ត ការបាត់បង់កិច្ចសន្យា

គ) ការបាត់បង់ ឬខូចខាតដោយសារកំហុសនៃការរចនា សម្ភារៈ ឬវត្ថុផលិតពីការចាក់ពុម្ពដែលមានខ្វះ ការងារទឹកដៃមិនល្អ លើកលែងតែកំហុសឆ្គងនៅពេលកំពុងតម្លើង

ឃ) ការសឹករេចរិល ច្រែះស៊ី អុក្ស៊ីទកម្ម ការឡើងក្រៀមរឹង

ង) ការបាត់បង់ ឬការខូចខាតចំពោះ ឯកសារ គំនូរ គណនី វិក្កយប័ត្រ ត្រា ប័ណ្ណកម្មសិទ្ធិ ភស្តុតាងបំណុល ប័ណ្ណមូលបត្រ ប័ណ្ណភាគហ៊ុន មូលប្បទានបត្រ សម្ភារៈសម្រាប់ខ្ចប់ ដូចជាកេស ប្រអប់ ឡាំង

ច) ការបាត់បង់ដែលត្រូវបានរកឃើញនៅពេលកំពុងធ្វើបញ្ជីសារពើភ័ណ្ឌ

ឆ) ការបាត់បង់ ឬការខូចខាតចំពោះអាគារដែលនៅជុំវិញ លើកលែងតែត្រូវបានផ្តល់នៅក្នុងចំនុចទី ″៥″ ក្រោម ′លក្ខខណ្ឌ′ អនុវត្តចំពោះផ្នែកទី ១ ខាងក្រោម។

**បទប្បញ្ញត្តិដែលអនុវត្តចំពោះផ្នែកទី ១**

**១. ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង**

វាជាលក្ខខណ្ឌតម្រូវនៃការធានារ៉ាប់រងនេះដែលថា ចំនួនទឹកប្រាក់ដែលត្រូវធានានៅក្នុងសេចក្តីលម្អិតពីរបស់ដែលត្រូវធានារ៉ាប់រង (schedule) មិនត្រូវមានចំនួនតិចជាងតម្លៃពេញនៃរបស់នីមួយៗនៅពេលដែលកិច្ចការសាងសង់បានបញ្ចប់ ដោយរួមបញ្ចូលទាំងថ្លៃដឹកជញ្ជូន ពាសុី ពន្ធគយ ការបង់ថ្លៃចំណាតផែ ថ្លៃតម្លើង ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវទទួលបន្ទុកបង្កើន និងបន្ថយបរិមាណនៃការធានារ៉ាប់រងនៅក្នុងហេតុការណ៍ដែលសម្ភារណាមួយមានការប្រែប្រួលចំពោះថ្លៃឈ្នួល និងតម្លៃ។

ការកើនឡើង ឬការថយចុះនេះចាប់មានប្រសិទ្ធភាព ដរាបណាការកើនឡើង ឬការថយចុះនេះត្រូវបានកត់ត្រាក្នុងកិច្ចសន្យាធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងជាមុនសិន។

ប្រសិនបើក្នុងករណីបាត់បង់ ឬខូចខាត គឺត្រូវបានរកឃើញថាចំនួនទឹកប្រាក់ដែលបានធានាតិចជាងចំនួនទឹកប្រាក់ដែលតម្រូវឲ្យដាក់ធានា ដូច្នេះចំនួនទឹកប្រាក់ដែលអាចធានាដោយបុគ្គលទទួលការធានារ៉ាប់រងតាមកិច្ចសន្យាធានារ៉ាប់រងនេះត្រូវកាត់បន្ថយតាមសមមាត្រនៃចំនួនទឹកប្រាក់ដែលបានធានា ទៅនឹងចំនួនទឹកប្រាក់ដែលតម្រូវឲ្យដាក់ធានា ។ រាល់វត្ថុ និងតម្លៃនៃទំនិញនឹងត្រូវស្ថិតនៅក្នុងលក្ខខណ្ឌនេះដាច់ដោយឡែកពីគ្នា ។

**២. មូលដ្ឋាននៃដំណោះស្រាយចំពោះការបាត់បង់**

ក្នុងករណីដែលមានការបាត់បង់ ឬខូចខាត មូលដ្ឋាននៃដំណោះស្រាយដែលមានចែងនៅក្នុងសន្យាធានារ៉ាប់រងនេះគឺ

i) ក្នុងករណីនៃការខូចខាតដែលអាចជួសជុលបាន - ដំណោះស្រាយជាមូលដ្ឋានគឺតម្លៃនៃការជួសជុលដែលចាំបាច់ដើម្បីស្តារទំនិញឲ្យត្រឡប់ទៅរកស្ថានភាពរបស់វាភ្លាមមុនពេលដែលទំនិញនោះរងការខូចខាត ដកតម្លៃស្រង់ដើម ឬ

ii) ក្នុងករណីដែលមានការខូចខាតទាំងស្រុង - ដំណោះស្រាយជាមូលដ្ឋានគឺតម្លៃទំនិញជាក់ស្តែងភ្លាមៗមុនពេលហេតុការណ៍នៃការ បាត់បង់ដោយដកតំលៃស្រង់ដើមចេញ ។

ទោះបីយ៉ាងណាក៏ដោយ លុះត្រាតែតម្លៃសំណងដែលត្រូវទាមទារចាំបាច់ត្រូវរ៉ាប់រងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងហើយលុះត្រាតែ តម្លៃនោះត្រូវបានរាប់បញ្ចូលទៅក្នុងចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង ហើយលុះត្រាតែបញ្ញត្តិ និងលក្ខខណ្ឌទាំងនោះត្រូវបានអនុវត្តតាម ។

ក្រុមហ៊ុនធានារ៉ាប់រងបង់ថ្លៃសំណងទូទាត់តែនៅពេលដែលមានវិក្កយប័ត្រសំខាន់ៗ និងឯកសារបញ្ជាក់ថាទំនិញនោះត្រូវខូច ឬមានការផ្លាស់ប្តូរតាមករណីដែលអាចកើតមាន ។
រាល់ការខូចខាតដែលអាចជួសជុលបានត្រូវធ្វើការជួសជុល ប៉ុន្តែ ប្រសិនបើតម្លៃជួសជុលការខូចខាតណាមួយដែលស្មើ ឬលើសពីតម្លៃនៃទំនិញ មុនពេលមានការខូចខាតកើតឡើងភ្លាមៗនោះ ត្រូវរកដំណោះស្រាយដោយផ្អែកលើមូលដ្ឋានដែលមានចែងនៅក្នុង ii) ខាងលើ ។

តម្លៃនៃការជួសជុលបណ្តោះអាសន្ននឹងជាបន្ទុករបស់ក្រុមហ៊ុនធានារ៉ាប់រង ប្រសិនបើការជួសជុលបែបនេះស្របទៅតាមផ្អែកនៃការជួសជុលចុងក្រោយ ហើយមិនមានការបង្កើនចំណាយសរុបលើការជួសជុលនោះទេ ។

តម្លៃនៃការផ្លាស់ប្តូរ ការបន្ថែម និង/ឬការធ្វើឲ្យប្រសើរឡើងណាមួយ មិនស្ថិតនៅក្រោមការធានារ៉ាប់រងរបស់កិច្ចសន្យាធានារ៉ាប់រង នេះឡើយ ។

### ៣. វិសាលភាពបន្ថែមនៃការធានារ៉ាប់រង

តម្លៃសេវាបន្ថែមនៃការងារម៉ោងបន្ថែម ការងារពេលយប់ ការងារធ្វើនៅថ្ងៃឈប់សំរាកបុណ្យជាតិ ការដឹកជញ្ជូនរហ័ស ត្រូវធានារ៉ាប់រងដោយកិច្ចសន្យាធានារ៉ាប់រងនេះ លុះត្រាតែមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរជាមុន និងជាពិសេស ។

### ៤. អាគារនៅជុំវិញ

ការបាត់បង់ ឬការខូចខាតចំពោះអាគារដែលមានទីតាំងនៅឯ ឬនៅជាប់នឹងកន្លែងការដ្ឋាន ហើយជាកម្មសិទ្ធិរបស់ ឬស្ថិតក្រោមការថែទាំ ឬអាណាព្យាបាលភាព ឬការឃុំគ្រងរបស់ភាគីប្បទាយី ឬអ្នកម៉ៅការ នឹងត្រូវបានធ្វើសំណង ប្រសិនបើកើតឡើងដោយមានទំនាក់ទំនងផ្ទាល់ទៅនឹងការតម្លើង ការសាងសង់ ឬការសាកល្បងរបស់ទាំងអស់នោះក្រោមផ្អែកទី១ និងកើតឡើងក្នុងអំឡុងរយៈពេលនៃការធានារ៉ាប់រង ហើយដរាបណាចំនួនទឹកប្រាក់ដាច់ដោយឡែកដែលត្រូវធានា ត្រូវបានចុះក្នុងសេចក្តីលម្អិតពីរបស់ដែលត្រូវធានារ៉ាប់រង (schedule)។ ការធានារ៉ាប់រងនេះមិនអនុវត្តចំពោះ ម៉ាស៊ីនសាងសង់ ឬម៉ាស៊ីនតម្លើង និងគ្រឿងចក្រសាងសង់ ឬគ្រឿងចក្រតម្លើង និងបរិក្ខារនោះឡើយ។

## <u>ផ្នែកទី ២ ~ ការទទួលខុសត្រូវចំពោះភាគីតតិយជន</u>

ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញសំណងដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងហូតដល់ ប៉ុន្តែមិនឲ្យលើសពីចំនួនដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធលើចំនួនទឹកប្រាក់សរុបដែលបុគ្គលដែលត្រូវបានធានារ៉ាប់រងទទួលខុសត្រូវក្នុងការបង់ជូននៅពេលមានការខូចខាតកើតឡើងជាលទ្ធផលនៃ

ក) របួសដោយចៃដន្យលើរាងកាយ ឬជំងឺរបស់តតីយជន (ទោះបណ្តាលអោយស្លាប់ ឬមិនស្លាប់ក៏ដោយ) ។

ខ) ការបាត់បង់ ឬ ខូចខាតដោយចៃដន្យលើទ្រព្យសម្បត្តិរបស់តតីយជន ។

ការកើតមាននូវការជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការតម្លើង ការសាងសង់ ឬការសាកល្បងតម្លើងវត្ថុដែលត្រូវបានធានានៅក្នុងផ្នែកទី ១ និងដែលកើត ឡើងនៅបរិវេណក្បែរៗការដ្ឋានក្នុងរយៈពេលនៃការធានារ៉ាប់រង ។

ចំពោះការទាមទារសំណងជំងឺចិត្តដែលសំណងទូទាត់នេះនឹងត្រូវអនុវត្ត ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សងបន្ថែមទៅកាន់បុគ្គលទទួលការធានារ៉ាប់រងចំពោះ

ក) រាល់ថ្លៃ និងការចំណាយលើបណ្តឹងដែលទាមទារដោយអ្នកទាមទារសំណងណាម្នាក់ពីបុគ្គលដែលត្រូវបានធានារ៉ាប់រង និង

ខ) រាល់ថ្លៃ និងការចំណាយដែលត្រូវរ៉ាប់រងដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនធានារ៉ាប់រង ។

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងផ្នែកនេះ មិនត្រូវលើសពីដែនកំណត់នៃសំណងដែលមានចែងនៅក្នុងឧបសម្ព័ន្ធឡើយ ។

**ការលើកលែងពិសេសចំពោះផ្នែកទី ២**

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនធានាសងបុគ្គលដែលត្រូវបានធានារ៉ាប់រងឡើយទាក់ទិននឹង :

១. ចំនួនកម្រិតមិនធ្វើសំណង ដែលមានចែងនៅក្នុងឧបសម្ព័ន្ធដែលត្រូវអនុវត្តដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង នៅក្នុងហេតុការណ៍ណាមួយ ។

២. ការចំណាយដែលអាចកើតមានក្នុងការធ្វើ ឬប៉ះប៉ូវ ឬជួសជុល ឬជំនួសអ្វីដែលបានធានារ៉ាប់រង ឬអាចធានារ៉ាប់រងដោយផ្នែកទី ១ នៃកិច្ចសន្យាធានារ៉ាប់រងនេះ ។

៣. ការទទួលខុសត្រូវចំពោះលទ្ធផលនៃ
   ក) របួសលើរាងកាយ ឬជំងឺរបស់បុគ្គលិក ឬអ្នកធ្វើការឲ្យអ្នកម៉ៅការសំណង់ ឬភាគីទទួលខុសត្រូវ ឬក្រុមហ៊ុនណាមួយដែលជាប់ពាក់ព័ន្ធនឹងគម្រោងដែល ឬផ្នែករបស់វាត្រូវបានធានារ៉ាប់រងដោយផ្នែកទី ១ ឬសមាជិកគ្រួសាររបស់ពួកគេ ។
   ខ) ការបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការថែរក្សារបស់អ្នកម៉ៅការសំណង់ ភាគីទទួលខុសត្រូវ ឬក្រុមហ៊ុនណាមួយដែលជាប់ពាក់ព័ន្ធនឹងគម្រោងដែល ឬផ្នែករបស់វាត្រូវបានធានារ៉ាប់រងដោយផ្នែកទី ១ ឬបុគ្គលិក ឬអ្នកធ្វើការរបស់អ្នកទាំងនោះណាមួយ ។
   គ) គ្រោះថ្នាក់ណាមួយដែលបង្កឡើងដោយយានយន្តដែលមានអាជ្ញាប័ណ្ណសម្រាប់ការប្រើប្រាស់លើផ្លូវទូទៅ កប៉ាល់ទឹក ឬយន្តហោះ ។
   ឃ) ការព្រមព្រៀងណាមួយដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងការបង់ប្រាក់ក្នុងលក្ខណៈធានាសំណងទូទាត់ ឬបើមិនដូច្នោះទេ ការទទួលខុសត្រូវបែបនេះក៏អាចភ្ជាប់ផងដែរនៅពេលដែលគ្មានការព្រមព្រៀងបែបនេះ ។

**លក្ខខណ្ឌពិសេសអនុវត្តចំពោះផ្នែកទី ២**

១. មិនមានការអនុញ្ញាតការផ្តល់អោយ ការសន្យាការបង់ប្រាក់ ឬការធានាសំណងណាមួយត្រូវបានធ្វើឡើងឬផ្តល់អោយដោយ ឬក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុនធានារ៉ាប់រង ដែលត្រូវមានសិទ្ធិឡើយប្រសិនបើពួកគេមានបំណងធ្វើដូច្នេះដើម្បីកាន់កាប់ និងធ្វើក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រង ការការពារ ឬដំណោះស្រាយនូវការប្តឹងទាមទារណាមួយ ឬដើម្បីសម្រេចឲ្យបានផលប្រយោជន៍ផ្ទាល់របស់ពួកគេក្នុងនាមបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវបណ្តឹងទាមទារការធានាសំណង ឬសំណងលើការខូចខាត បើមិនដូច្នោះទេត្រូវមានឆន្ទានុសិទ្ធិពេញលេញក្នុងការប្រតិបត្តិដំណើរការណាមួយ ឬនៅក្នុងការដោះស្រាយចំពោះការប្តឹងទាមទារណាមួយ ហើយបុគ្គលដែលត្រូវបានធានារ៉ាប់រងត្រូវផ្តល់ជូននូវព័ត៌មាន និងជំនួយបែបនេះតាមដែលក្រុមហ៊ុនធានារ៉ាប់រងអាចត្រូវការ ។

២. ក្រុមហ៊ុនធានារ៉ាប់រងអាចសងទៅបុគ្គលដែលត្រូវបានធានារ៉ាប់រងចំពោះគ្រោះថ្នាក់ទាំងឡាយដែលពាក់ព័ន្ធ នូវសំណងទូទាត់ចំពោះគ្រោះថ្នាក់ណាមួយ (ប៉ុន្តែកាត់រំលោះចេញនូវទឹកប្រាក់មួយចំនួនចំពោះករណីបែបនេះ ឬទឹកប្រាក់ដែលបានសងជាសំណងជំងឺចិត្តចំពោះករណីនេះរួចហើយ) ឬចំនួនទឹកប្រាក់ដែលតិចជាងនេះសម្រាប់បណ្តឹងទាមទារដែលកើតចេញពីគ្រោះថ្នាក់ដែលអាចដោះស្រាយបាន រីឯក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលខុសត្រូវទៀតឡើយចំពោះគ្រោះថ្នាក់បែបនេះនៅក្នុងផ្នែកនេះ ។